**អង្គការសមាគមធាងត្នោត**

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

លេខ:....០៩៥/២៣.....

# សេចក្តីប្រកាសជ្រើសរើសសន្តិសុខ

អង្គការសមាគមធាងត្នោត គឺជាអង្គការឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ បានបង្កើតឡើងតាំងពីឆ្នាំ២០០៥ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦។

អង្គការសមាគមធាងត្នោងមានគម្រោងប្រកាសជ្រើសរើសស្វែងរកក្រុមហ៊ុននានាដើម្បីចូលរួមដាក់ពាក្យផ្គត់ផ្គង់អ្នកយាមការិយាល័យនៅពេលយប់ (ច័ន្ទ ដល់ សុក្រ) ថ្ងៃបុណ្យជាតិនានា និងថ្ងៃចុងសប្តាហ៍ (សៅរ៍ និង អាទិត្យ) ។

**លក្ខខណ្ឌដែលក្រុមហ៊ុនត្រូវមាន៖**

- លិខិតប្រកបអាជីវកម្ម ឬ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬ ប័ណ្ណប៉ាតង់ ដែលមានសុពលភាព
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (ក្នុងករណីដែលពុំបានចុះបញ្ជីពន្ធដារ ត្រូវផ្តល់សម្រង់តម្លៃដោយមិនគិតបញ្ចូលពន្ធ)
- លិខិតបញ្ជាក់ទីតាំងក្រុមហ៊ុន និង អត្តសញ្ញាណប័ណ្ណម្ចាស់ក្រុមហ៊ុន
- ផ្តល់លិខិតសម្រង់តម្លៃ

**បែបបទនៃការដាក់ពាក្យ៖**

ប្រសិនបើលោក-លោកស្រីដែលជាម្ចាស់ក្រុមហ៊ុននានា មានចំណាប់អារម្មណ៍ក្នុងការដាក់ពាក្យ សូមផ្តល់នូវលិខិតសម្រង់តម្លៃ ដោយភ្ជាប់ជាមួយនឹងឯកសារច្បាប់នានាដែលបានតម្រូវក្នុងលក្ខខណ្ឌខាងលើ **ដាក់ក្នុងស្រោមសំបុត្របិទជិត** រួចផ្ញើមកកាន់អង្គការសមាគមធាងត្នោត ដែលមានអាសយដ្ឋាន ផ្ទះលេខ ៧ ផ្លូវលេខ ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់លេខទូរស័ព្ទ៖ **០២៣ ៤៣១ ៥៥៥** **Email: recruitment@teangtnaut.org**

**កាលបរិច្ឆេទឈប់ទទួលពាក្យ៖**

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១២ ថ្ងៃត្រង់ ។

**ប្រធានផ្នែករដ្ឋបាល និងធនធានមនុស្ស**

Sahmakum Teang Tnaut Organization

**លោក សួស សុភាព**

**កាលបរិច្ឆេទ ៖** ១១...មេសា...២០២៣

អាសយដ្ឋាន៖ ផ្ទះលេខ ៧ ផ្លូវលេខ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរសព្ទលេខ (៨៥៥)២៣ ៤៣១ ៥៥៥
ប្រអប់សំបុត្រលេខ ១៧៤ ភ្នំពេញ កម្ពុជា អ៊ីមែល info@teangtnaut.org គេហទំព័រ: www.teangtnaut.org
Address: #7, St 494, Phsar Daeum Thkov, Chamkar Mon, Phnom Penh. Tel: (855)23 431 555
P.O. Box 174, Phnom Penh, Cambodia. E-mail. info@teangtnaut.org Web. www.teangtnaut.org

## សន្តិសុខ
## យាមការិយាល័យនៃអង្គការសហគមន៍ធាងត្នោត

### ❖ តួនាទី និង ទំនួលខុសត្រូវលើការងារ

- យាមល្បាតបរិវេណការិយាល័យ ធានានូវសុខសុវត្ថិភាព
- ធ្វើការរាយការណ៍ជាបន្ទាន់ដល់ប្រធានរដ្ឋបាល និងធនធានមនុស្ស នៅពេលមានករណីគ្រោះអាសន្ន អគ្គីភ័យ ចោរកម្ម និងទំនាក់ទំនងទៅភ្នាក់ងារពន្លត់អគ្គីភ័យ សង្គ្រោះបន្ទាន់ ប៉ូលីស ដើម្បីចុះអន្តរាគមន៍
- ពិនិត្យមើលទ្វារ និងបង្អួចការិយាល័យ ធានាថាបានបិទ និងចាក់សោរត្រឹមត្រូវ
- ពេលមានអ្នកខាងក្រៅយកលិខិតមកដាក់ត្រូវយកទៅឱ្យប្រធានរដ្ឋបាល
- សំអាតបរិវេណជុំវិញអាគារ មុខការិយាល័យ និងយកសម្រាមដាក់ឡាន ស៊ិនទ្រី
- ថែទាំ និងស្រោចទឹកសំអាតបរិវេន និងខាងមុខការិយាល័យ
- ថែរក្សាសុវត្ថិភាពជូនបុគ្គលិក និងអតិថិជន ដែលកំពុងស្ថិតនៅក្នុងការិយាល័យ

### ❖ លក្ខខណ្ឌតម្រូវ

- ភេទប្រុស
- មានអត្តចរិត និងមានសីលធម៌ការងារល្អ
- មានភាពស្មោះត្រង់ ហ្មឺងម៉ាត់ ហ្មត់ចត់
- អាចធ្វើការងារជាក្រុមជាមួយបុគ្គលិកដទៃបាន
- មានឆន្ទៈមោះមុតចំពោះការងារ

អាសយដ្ឋាន៖ ផ្ទះលេខ ៧ ផ្លូវលេខ៤៩៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរសព្ទលេខ (៨៥៥)២៣ ៤៣១ ៥៥៥
ប្រអប់សំបុត្រលេខ ១៧៤ ភ្នំពេញ កម្ពុជា អ៊ីមែល info@teangtnaut.org គេហទំព័រ: www.teangtnaut.org
Address: #7, St 494, Phsar Daeum Thkov, Chamkar Mon, Phnom Penh. Tel: (855)23 431 555
P.O. Box 174, Phnom Penh, Cambodia. E-mail. info@teangtnaut.org Web. www.teangtnaut.org